# ការអប់រំរបស់លោកអភិបាល អូលីវីយេ
# អំពីអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង
# ទិវាគ្រួសារនៅភ្នំពេញថ្មី ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩
## គ្រួសារជាមូលដ្ឋាននៃសង្គមនិងព្រះសហគមន៍

នេះជាលើកទី១ ដែលយើងបានប្រមូលទាំងគ្រួសារ មានទាំងឪពុកទាំងម្តាយទាំងកូនទាំងលោកតាទាំងលោកយាយ ក្នុងភូមិភាគភ្នំពេញទាំងមូល។ ដូច្នេះ ថ្ងៃនេះជាថ្ងៃសម្រាប់គ្រួសាររបស់បងប្អូនដើម្បីសូមឲ្យរួមគ្នា យើងទទួលព្រះពរពីព្រះជាម្ចាស់តាមរយៈសន្ត លូវីស សន្តី ហ្សឺលី និងសន្តី តេរេសានៃព្រះកុមារយេស៊ូ ជាពិសេសតាមរយៈគ្រួសារដ៏វិសុទ្ធ។ ថ្ងៃនេះ យើងមានគ្រួសារគំរូបំផុតដែលជាប្រភពនៃជីវិតរបស់យើងជាក្រុមគ្រួសារ គឺគ្រួសារដ៏វិសុទ្ធ មានសន្តយ៉ូសែប ព្រះនាងម៉ារី និងព្រះយេស៊ូ ដែលជាប្រភពនៃគ្រួសារទាំងអស់។ ជួនកាលពេលយើងនិយាយអំពីគ្រួសារដ៏វិសុទ្ធ មានអារម្មណ៍ថាគ្រួសារយើងអត់ទាន់ដ៏វិសុទ្ធ យើងមានអារម្មណ៍ថា **តើយើងធ្វើយ៉ាងម៉េចដូចគ្រួសារហ្នឹង**? **តើយើងធ្វើយ៉ាងម៉េចដើម្បីមានសេចក្តីសុខសាន្តដូចគ្រួសារហ្នឹង**? ដោយសារក្នុងគ្រួសារហ្នឹងមានព្រះជាម្ចាស់ផ្ទាល់ យើងមានព្រះនាងម៉ារីដែលចូលស្ថានបរមសុខមុនគេបង្អស់ ដូច្នេះប្រហែលយើងអត់វិសុទ្ធទេហួសពីកម្រិតរបស់យើង។

គ្រួសារយើងត្រូវការមានកម្លាំង ឥលូវយើងមានគ្រួសារដ៏វិសុទ្ធមួយទៀតដែលនៅទីនេះ គឺយើងមានសន្ត លូវីស និងសន្តី ហ្សឺលី រួមជាមួយសន្តីតេរេសានៃព្រះកុមារយេស៊ូ ដែលជាកូនបង្កើត។ នេះជាគ្រួសារដ៏វិសុទ្ធមួយទៀត ដែលប្រហែលជិតស្និទ្ធនឹងយើងជាង ដោយសារជាគ្រួសារដែលរស់នៅជាង១០០ឆ្នាំមុន និងជាគ្រួសារមួយដែលរស់នៅក្នុងជីវិតសាមញ្ញធម្មតា។ អត់មានព្រះជាម្ចាស់ អត់មានព្រះនាងម៉ារី ប៉ុន្តែគេយកកម្លាំងពីព្រះជាម្ចាស់មានន័យថាពីគ្រួសារដ៏វិសុទ្ធ។ ដូច្នេះ ថ្ងៃនេះជាថ្ងៃរបស់យើងដែលជាក្រុមគ្រួសារ នៅលើកោដ្ឋនេះមានចិញ្ចៀន២វង់ដើម្បីនឹកឃើញអគ្គសញ្ញាអាពាហ៍ពិពាហ៍ដែលយើងបានទទួល។ ខ្ញុំនឹកឃើញដល់ឪពុកម្តាយខ្ញុំដែលបានរៀបការ៥០ឆ្នាំហើយ គាត់បានថែរក្សាចិញ្ចៀនរបស់គាត់រហូត។ នេះជាសញ្ញាសម្គាល់មួយ ដែលសំខាន់ដោយសារពីមួយថ្ងៃទៅមួយថ្ងៃប្រសិនបើយើងថែរក្សាចិញ្ចៀនរបស់យើងណែនាំឲ្យយើងនឹកឃើញប្រពន្ធ នឹកឃើញប្តី នឹកឃើញថ្ងៃដំបូងដែលយើងបានជួបគ្នា។ ដូច២នាក់នេះថ្ងៃដំបូងដែលគេបានជួបគ្នាមិនអាចភ្លេចទេ ហ្សឺលី ដែលចង់ធ្វើជាបងស្រី លូវីស ដែលចង់ធ្វើជាបូជាចារ្យ តែអត់ជោគជ័យដូចគ្នា។ ដូច្នេះ គេបានទៅរកស៊ីរៀងៗខ្លួន លូវីស គាត់ទៅធ្វើជាជាងនាឡិកា ហ្សឺលី គាត់ជាជាងប៉ាក់ មានថ្ងៃមួយគេដើរលេងលើស្ពាន ហើយមើលមុខគ្នាបេះដូងក៏លោតខ្លាំងៗហើយយល់ថានេះជាប្តីខ្ញុំ នេះជាប្រពន្ធខ្ញុំទៅថ្ងៃអនាគត។

ដូច្នេះថ្ងៃនេះ ឲ្យយើងនឹកឃើញថ្ងៃដែលយើងបានជួបគ្នា ទោះបីយើងជួបគ្នា១ឆ្នាំ ១០ឆ្នាំ ២០ឆ្នាំ ៥០ឆ្នាំហើយ យើងមិនអាចភ្លេចបានទេមួយជីវិតយើង។ ឲ្យនឹកឃើញថ្ងៃដែលយើងជួបគ្នាលើកទី១ ឲ្យនឹកឃើញថ្ងៃដែលយើងរៀបការ និងអរព្រះគុណព្រះជាម្ចាស់សម្រាប់ថ្ងៃនោះ។ ថ្ងៃនេះ ជាថ្ងៃដែលព្រះជាម្ចាស់ប្រទានពរឲ្យគ្រួសាររបស់យើង យើងមានព្រះពរពិសេសសម្រាប់គ្រួសារនីមួយៗ និងខ្ញុំជូនគ្រួសារដ៏វិសុទ្ធដល់គ្រួសារនីមួយៗ ដើម្បីទុកនៅក្នុងផ្ទះឲ្យយើងនឹកឃើញជីវិតយើងជាប្តីប្រពន្ធដែលបានទទួលស្វាគមន៍កូន។ យើងក៏នឹងទទួលបានប័ណ្ណព្រះពរដើម្បីនឹកឃើញដល់ថ្ងៃនេះ និងដើម្បីឲ្យព្រះជាម្ចាស់ការពារថែរក្សាជីវិតរបស់យើងជាប្តីប្រពន្ធ។ ដើម្បីឲ្យយើងនឹកឃើញដល់ជីវិតរបស់យើង ស្របតាមជីវិតរបស់សន្ត លូវីស និងសន្តី ហ្សេលី។ យើងអាចនិយាយថាគ្រួសារនេះជាគ្រួសារទំនើប ដោយសារគេរស់នៅក្នុងបច្ចុប្បន្នយើង និងយល់ចិត្តរបស់យើងយ៉ាងច្រើន។ កុំភ្លេចគ្រួសារជាមូលដ្ឋាននៃសង្គម សង្គមមួយកើតឡើងដោយសារគ្រួសារនីមួយៗភ្ជាប់គ្នា ហេតុនេះហើយនៅពេលគ្រួសារមានសេចក្តីសុខ សង្គមមានសេចក្តីសុខ។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ គ្រួសារនីមួយៗជាមូលដ្ឋាននៃព្រះសហគមន៍ គ្រួសារនីមួយៗភ្ជាប់គ្នាទៅជាព្រះសហគមន៍ ថ្ងៃនេះខ្ញុំរំភើបណាស់ដោយសារខ្ញុំឃើញមានបងប្អូនជាច្រើនគូដែលអង្គុយនៅមុខ (សូមប្តីទះដៃជូនប្រពន្ធ សូមប្រពន្ធទះដៃជូនប្តី សូមកូនៗទះដៃជូនឪពុកម្តាយ) នេះជាមូលដ្ឋាននៃព្រះសហគមន៍ដែលមានជីវិត។ ព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ដើម្បីឲ្យយើងរៀបការ ឲ្យយើងមានកូន និងឲ្យយើងថែរក្សា។

គ្រួសារដែលយើងមាននៅទីនេះ ជាគ្រួសារមួយដ៏សុខសាន្ត ប៉ុន្តែសុខសាន្តអត់មានន័យថាមានសេចក្តីសុខរហូត ឈ្លោះគ្នាក៏មាន បញ្ហាក៏មាន ទុក្ខលំបាកក៏មាន ទុក្ខលំបាកមួយយ៉ាងធំដែលគេជួបគឺមានកូន៤នាក់បានស្លាប់។ ទុក្ខលំបាកមួយធំបំផុតនៅក្នុងគ្រួសារហ្នឹង គឺម្តាយស្លាប់នៅអាយុ៤៦ឆ្នាំ ដោយសារជំងឺមហារីកសុដន។ នៅពេលហ្នឹងកូនតេរេសាមានអាយុតែ៤ឆ្នាំ មានន័យថាគ្រួសារហ្នឹង មានបទពិសោធន៍នៅក្នុងទុក្ខលំបាកយ៉ាងច្រើនដូចយើង។

ខ្ញុំមាន៦ចំណុច សម្រាប់ជីវិតយើងជាគ្រួសារ គឺៈ

ទី១ **ប្តីប្រពន្ធដែលស្រឡាញ់គ្នាទៅវិញទៅមក** ដោយសារយើងចាំថ្ងៃស្នេហាដំបូង ថ្ងៃដែលយើងជួបគ្នាលើកទី១ សំខាន់បំផុតគឺប្តីប្រពន្ធស្រឡាញ់គ្នា ត្រូវការបង្ហាញសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់រវាងគ្នានិងគ្នាយូរៗម្តង កុំឲ្យយើងនឹកឃើញតែមុនរៀបការ។ គ្រួសារនេះ លូវីស គាត់ធ្វើដំណើរច្រើនដើម្បីរកស៊ី ប៉ុន្តែនៅសម័យហ្នឹងតែសរសេរសំបុត្រ គេបានសរសេរសំបុត្រឲ្យគ្នាទៅវិញទៅមក "**បងអើយខ្ញុំនឹកបងណាស់ អូនចាំបងត្រឡប់មកវិញឆាប់ៗ អូនប្រៀបដូចជាត្រីដែលចេញពីទឹកនៅពេលបងអត់នៅផ្ទះ**"។ ហ្សេលី គាត់សរសេរទៅប្តីគាត់ថា "**អូនដូចជាត្រីមួយ**

**ក្បាលដែលចេញពីទឹកនៅពេលបងទៅឆ្ងាយ**" គាត់សរសេរថែមទៀតថា "**ថ្ងៃនេះអូនត្រេកអរពេក ពេលដឹងថាបងត្រឡប់មកវិញ អូនធ្វើការមិនកើតទន្ទឹងរង់ចាំបង**"។ សព្វថ្ងៃ ស្រួលណាស់អត់ត្រូវការផ្ញើសំបុត្រទេ យើងសរសេរសារមួយ រូបភាពមួយ ផ្ញើតាមទូរស័ព្ទដៃ ដើម្បីបង្ហាញអារម្មណ៍ដែលមានចំពោះគ្នានឹងគ្នា។ កុំភ្លេចថ្ងៃខួបកំណើត ថ្ងៃខួបអាពាហ៍ពិពាហ៍ ថ្ងៃសន្តុសន្តិផ្ទាល់ខ្លួន ជូនកាដូតិចតួចទៅ ផ្កាមួយទង សូកូឡាមួយប្រអប់ ថើបមួយ...។ តាំងពីខ្ញុំនៅក្មេងរហូតដល់ពេលនេះ ខ្ញុំអត់ដែលឃើញឪពុកខ្ញុំភ្លេចជូនកាដូទៅម្ដាយខ្ញុំ ក្នុងថ្ងៃខួបកំណើត ខួបអាពាហ៍ពិពាហ៍ ថ្ងៃបុណ្យសន្តិម្ដាយ ប៉ុន្តែខ្ញុំក៏បានឃើញឪពុកម្ដាយខ្ញុំឈ្លោះគ្នាដែរ ម្ដាយខ្ញុំស្ដីឲ្យប៉ាខ្ញុំ ប៉ុន្តែនេះសញ្ញាសម្គាល់នៃសេចក្ដីស្រឡាញ់ ឲ្យមានការលើកលែងទោសគ្នាទៅវិញទៅមក។ ដូច្នេះ ជាមូលដ្ឋានទី១ ធ្វើយ៉ាងម៉េចដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់យើងជាប្ដីប្រពន្ធអស់មួយជីវិត។

ទី២ **ឲ្យយើងទទួលស្វាគមន៍ជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យ** ព្រះសហគមន៍យើងណែនាំឲ្យយើងថែរក្សាជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យ។ មានខ្លះចង់មានកូនតែអត់មាន មានខ្លះអត់ចង់មានកូនតែមានច្រើនពេក មានខ្លះប្រើថ្នាំដើម្បីការពារ មានខ្លះគេសម្លាប់កូននៅក្នុងផ្ទៃពោះ។ ដូច្នេះ ឲ្យយើងនឹកឃើញជីវិតជាគម្រោងការណ៍របស់ព្រះជាម្ចាស់ ដូច្នេះនេះសំខាន់ទទួលជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យនៅក្នុងអំណរសប្បាយ ប្រសិនបើយើងជឿលើព្រះជាម្ចាស់ ព្រះជាម្ចាស់ថែរក្សា។

ទី៣ **អប់រំ ថែរក្សាកូន** ជីវិតដែលយើងទទួលពីព្រះជាម្ចាស់ ជាព្រះអំណោយទានមួយយ៉ាងពិសេស ពេលយើងទទួលជីវិតហ្នឹងហើយឲ្យយើងធ្វើយ៉ាងម៉េចដើម្បីអប់រំ យើងត្រូវការអប់រំកូនៗរបស់យើង។ សព្វថ្ងៃខ្ញុំចាប់អារម្មណ៍អំពីប្ដីប្រពន្ធទំនើបៗ គឺទាំងឪពុកទាំងម្ដាយធ្វើការ សង្គមបច្ចុប្បន្ននេះចង់ឲ្យម្ដាយធ្វើការដូច្នេះទាំងប៉ាទាំងម៉ែធ្វើការចុះកូន? ឲ្យយើងទុកកូននៅឯណា? ផ្ញើនៅជាមួយយាយ ជួនកាលយាយនៅឆ្ងាយណាស់ យើងនៅភ្នំពេញតែយាយនៅកំពត យើងនៅភ្នំពេញតែយាយនៅតាកែវ... យើងផ្ញើកូនឲ្យយាយតា នឹងប៉ាម៉ាក់យូរៗទៅម្ដង។ ក្រោយមកពេលកូនមានអាយុ១ឆ្នាំ យើងផ្ញើកូនទៅសាលា សព្វថ្ងៃប្ដីគាត់ជួយប្រពន្ធច្រើនដើម្បីថែរក្សាកូន ដូច្នេះសំខាន់យើងជាប៉ាម៉ាក់ធ្វើយ៉ាងម៉េចដើម្បីអប់រំកូនរបស់យើង។ កូនរបស់យើងជាទ្រព្យសម្បត្តិដែលយើងបានទទួល ជាអនាគតមួយយ៉ាងពិសេស គេត្រូវការភាពកក់ក្ដៅពីឪពុកម្ដាយ។

ទី៤ **យកចិត្តទុកដាក់ឲ្យយើងមានទឹកចិត្តម្ដាយ ទឹកចិត្តឪពុក** កាលៈទេសៈនៃជីវិត បញ្ហានៃជីវិត បញ្ហាលុយ បញ្ហាសុខភាព បញ្ហាការងារ... នៅប្រទេសកម្ពុជាយើងមានគ្រួសារច្រើនដែលចេញទៅធ្វើការនៅប្រទេសថៃ ផ្ញើកូនទៅតាយាយ។ ប៉ុន្តែដូច លូវីស និង ហ្សីលី យើងអាចនិយាយថា ហ្សីលី មានទឹកចិត្តម្ដាយយ៉ាងខ្លាំងណាស់ លូវីស មានទឹកចិត្តឪពុកយ៉ាងខ្លាំងណាស់

លូវីស និង ហ្សីលី បានយកចិត្តទុកដាក់ដើម្បីអប់រំកូន។ ហ្សីលី ពេលគាត់នៅក្មេងគាត់មិនដែលស្គាល់សេចក្ដីស្រឡាញ់ពីឪពុកម្ដាយគាត់ទេ ម្ដាយគាត់អត់ចូលចិត្តគាត់ទេ អាចនិយាយបានថាម្ដាយគាត់ស្អប់គាត់ ម្ដាយមិនដែលមើលគាត់ទេ មិនដែលមានភាពកក់ក្ដៅនៅក្នុងគ្រួសារ។ ក៏ប៉ុន្តែនៅពេល ហ្សីលី ទៅជាម្ដាយគាត់បានយកចិត្តទុកដាក់អប់រំកូន មិនឲ្យកូនគាត់មានបទពិសោធន៍ដូចគាត់នៅក្មេង។ ជួនកាល យើងមានបទពិសោធន៍ពិបាកជាមួយឪពុកម្ដាយរបស់យើង ប៉ុន្តែនៅពេលយើងមានកូន យើងមិនអាចយកបទពិសោធន៍របស់យើងទៅជាមូលដ្ឋានផ្ទុយទៅវិញយើងនឹកឃើញយើងមានគ្រួសារដ៏វិសុទ្ធ មានគ្រួសារគំរូនៅក្នុងព្រះសហគមន៍កាតូលិកដើម្បីជួយយើង ដើម្បីមានកម្លាំងបង្ហាញសេចក្ដីស្រឡាញ់ដល់កូនៗរបស់យើង។

ទី៥ **ឲ្យគ្រួសាររបស់យើងរកឃើញកម្លាំងនៅក្នុងព្រះជាម្ចាស់** យើងជាគ្រីស្ដបរិស័ទកាតូលិក យើងត្រូវការរកឃើញកម្លាំងនៅក្នុងព្រះជាម្ចាស់។ គ្រួសារនេះដែលជាគ្រួសារដ៏វិសុទ្ធ បានរកឃើញកម្លាំងនៅក្នុងការអធិដ្ឋាន ព្រឹកឡើងម៉ោង៥កន្លះចូលអភិបូជា រាល់ថ្ងៃពេលពាក់អាវឲ្យកូនៗនិយាយអំពីរឿងព្រះយេស៊ូ បពិត្រព្រះនាងម៉ារី ឱព្រះបិតាអើយ… ដើម្បីឲ្យកូនចូលនៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់។ អត់មានអ្វីអស្ចារ្យប៉ុន្មានទេគិតទៅ គេនិទានរឿងអំពីព្រះយេស៊ូតិចៗ គេបង្រៀនកូនឲ្យគូសសញ្ញាឈើឆ្កាង…។ អធិដ្ឋានជាលក្ខណៈគ្រួសារ ចាប់ពីពេលនេះតទៅឲ្យផ្ទះនីមួយៗមានតុអាសនៈមួយដើម្បីតាំងព្រះនាងម៉ារី ឈើឆ្កាង និងគ្រួសារដ៏វិសុទ្ធ ឲ្យជួបជុំគ្នាជាគ្រួសារដើម្បីអធិដ្ឋាន។ ពេលខ្ញុំនៅក្មេង រាល់ថ្ងៃអាទិត្យឪពុកម្ដាយខ្ញុំណែនាំខ្ញុំឲ្យចូលវិហារមិនដែលខានទេ នៅពេលរដូវ៤០ថ្ងៃថ្ងៃអាទិត្យពេលល្ងាចយើងអធិដ្ឋានជាលក្ខណៈគ្រួសារ។ ដូច្នេះ ទោះបីយើងអត់ធ្វើរាល់អាទិត្យ ប៉ុន្តែឲ្យយើងមានពេលអធិដ្ឋានជាលក្ខណៈគ្រួសារកុំឲ្យយើងភ្លេច កុំឲ្យយើងយកទ្រព្យសម្បត្តិជាអាទិភាពនៃជីវិតរបស់យើង។ ពេលខ្ញុំបានធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារពេលព្រឹកឲ្យគ្រីស្ដបរិស័ទម្នាក់នៅចំការទៀង ក្រោយមកពេលល្ងាចខ្ញុំទៅញ៉ាំការនៅពេលនោះមានមីងម្នាក់ជាអ្នករកស៊ី គាត់និយាយមកខ្ញុំថា "**លោកឪពុក ខ្ញុំជាពុទ្ធបរិស័ទព្រឹកមិញខ្ញុំបានស្ដាប់លោកឪពុកទេសនា អំពីសេចក្ដីស្រឡាញ់រវាងប្ដីប្រពន្ធ ខ្ញុំការ២០ឆ្នាំហើយខ្ញុំចេះតែជេរប្ដីខ្ញុំពីព្រឹកដល់យប់ អត់ដែលនិយាយទៅប្ដីថា ខ្ញុំស្រឡាញ់ឯង ពេលស្ដាប់លោកឪពុកហើយខ្ញុំនឹកឃើញ២០ឆ្នាំអត់ដែលនិយាយថា ខ្ញុំស្រឡាញ់បង ល្ងាចពេលខ្ញុំទៅផ្ទះវិញខ្ញុំគិតថាខ្ញុំនឹងប្រាប់ប្ដីខ្ញុំថា ខ្ញុំស្រឡាញ់បង**"។ សេចក្ដីស្រឡាញ់កុំឲ្យយើងគិតតែពីលោកិយ៍ ប៉ុន្តែឲ្យយើងនឹកឃើញដល់មូលដ្ឋាននៃជីវិត គឺសេចក្ដីស្រឡាញ់ពីព្រះជាម្ចាស់ជាកម្លាំងដើម្បីទៅមុខ។

ទី៦ **កុំឲ្យគ្រួសាររបស់យើងទៅជាគ្រួសារចង្អៀតចង្អល់** ដោយសារយើងអាចទៅជាគ្រួសារចង្អៀតចង្អល់ ដែលមានតែប្ដីប្រពន្ធកូន អត្មានិយម។ ឲ្យយើងទុកពេលវេលា ដើម្បីបើកចិត្តគំនិត

ទូលំទូលាយដល់អ្នកដទៃដែរ គ្រួសារដ៏វិសុទ្ធហ្នឹងរាល់ថ្ងៃចន្ទពេលរសៀលគេបើកទ្វារផ្ទះដើម្បីទទួលអ្នកក្រីក្រ និងគេចែកអំណោយលើកទឹកចិត្តអ្នកក្រីក្រ។ ដូច្នេះ យើងត្រូវការគិតដែរ គ្រួសារខ្ញុំនៅពេលមានកូនមានប្ដីប្រពន្ធហើយ ឲ្យខ្ញុំចេះនឹកឃើញដល់បងប្អូនឯទៀតៗដែលក្រីក្រ ដែលមានទុក្ខលំបាក ជាពិសេសដល់គ្រួសារដែលមានទុក្ខលំបាក។ គ្រួសារដែលមានសេចក្ដីសុខ ឲ្យទៅជាគ្រួសារដែលចេះលើកទឹកចិត្តដល់គ្រួសារដែលមានទុក្ខលំបាក។ ទីប្រឹក្សានៃគ្រួសារដទៃគឺគ្រួសារ មិនមែនបូជាចារ្យប៉ុន្មានទេ ដូច្នេះឲ្យយើងចែកបទពិសោធន៍គ្រួសារយើង ឲ្យយើងបើកចិត្តគំនិតទូលំទូលាយដល់អ្នកក្រីក្រ ដើម្បីឲ្យគ្រួសាររបស់យើងជាគ្រួសារទូលំទូលាយ។

គ្រួសារជាមូលដ្ឋាននៃសង្គមនិងព្រះសហគមន៍ ទី១ ឲ្យប្ដីប្រពន្ធបង្ហាញសញ្ញាសម្គាល់ស្រឡាញ់គ្នាទៅវិញទៅមក ទី២ ទទួលជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យ ទី៣ អប់រំ ថែរក្សាកូន ទី៤ យកចិត្តទុកដាក់ឲ្យយើងមានទឹកចិត្តម្ដាយ ទឹកចិត្តឪពុក ទី៥ ឲ្យយើងរស់នៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែលជាប្រភពដើម្បីទៅមុខ ទី៦ ឲ្យយើងមានគ្រួសារដែលទូលំទូលាយ ដើម្បីនឹកឃើញដល់អ្នកដទៃ នឹកឃើញដល់អ្នកក្រីក្រ នឹកឃើញដល់គ្រួសារដែលមានទុក្ខលំបាក នឹកឃើញដល់អ្នកដែលនៅជុំវិញយើង។ ជម្ងឺនៃសង្គមទំនើប គឺភាពឯកោ សង្គមខ្មែរពីដើមគ្មានភាពឯកោទេ ភូមិមួយជាគ្រួសារមួយ យើងស្គាល់គ្នាច្បាស់។ ប៉ុន្តែ បច្ចុប្បន្ននេះគ្រួសារមួយគឺគ្រួសារឯកោបន្តិច ដូច្នេះយើងត្រូវការប្រុងប្រយ័ត្នសម្រាប់គ្រួសារយើងជាគ្រីស្តបរិស័ទបើកចិត្តគំនិតទូលំទូលាយដើម្បីបង្កើតសេចក្ដីសុខ។